# ការសម្ភាសរបស់លោកយាយ យ៉ង់ រី

កៈ អ្នកសម្ភាសឈ្មោះដាង ស៊ីអ៊ារ ខៈ អ្នកទទួលការសម្ភាសឈ្មោះយ៉ង់ រី

## <u>ការសង្ខេបប្រវត្តិរបស់លោកយាយ យ៉ង់ រី</u>

យ៉ង់ រី មានអាយុ ៦៨ឆ្នាំនៅក្នុងឆ្នាំ២០១៩ មានភេទ
មានទីលំនៅបច្ចុប្បន្ននៅភូមិយ៉បាត សង្កាត់ក្បាលកោះ ខ័ណ្ឌច្បារអំពៅ រាជធានៅភ្នំពេញ។

កៈ
ចឹងជាដំបូងខ្ញុំអរគុណច្រើនយាយដែរបានអោយខ្ញុំពិភាក្សាជាមួយយាយទាក់ទងពីប្រវត្តិរបស់យាយ
ហើយការសម្ភាសទាំងអស់នេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU
ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅជំនាន់ក្រោយពួកគាត់បានស្គាល់ហ្នឹងបានដឹងពីប្រវត្តិឪពុកម្ដាយហ្នឹងដូនតាចឹងសំរាប់យាយយល់ព្រម
ដើម្បីអោយចៅដាក់ការសម្ភាសទាំងអស់ហ្នឹងទៅក្នុងវេបសាយសាលាទេយាយ?

ខៈ ខ្ញុំជាមនុស្សមិនចេះនិយាយនិយាយទៅ។

កៈ អូ៎!

ខៈ ប្រវត្តិយាយឯងមួយប្ដីប្រពន្ធម៉េចទៅ។

កៈ យាយអាចរៀបរាប់តាមអ្វីដែរយាយអាចចាំប៉ុណ្ណឹងហាសយាយ
យាយចាំបានប៉ុណ្ណាយាយនិយាយប៉ុណ្ណឹងហាសយាយ?

ខៈ ខ្ញុំប្រវត្តិខ្ញុំមានតែពីរនាក់ប្ដីប្រពន្ធកាន់ចាប់ដៃគ្នាមកខ្ញុំធ្វើចំការ។

កៈ អូ៎យាយធ្វើចំការរហូតហោស?

ខៈ ចា៎!

កៈ ចឹងអត់អីទេណេះយាយបាទចឹងសំរាប់ខ្ញុំជាអ្នកសម្ភាសយាយខ្ញុំមានឈ្មោះថាដាង
ស៊ីអ៊ារហើយថ្ងៃខែដែរខ្ញុំសម្ភាសយាយគឺនៅថ្ងៃទី៣១ខែ១ឆ្នាំ២០១៩
ហើយការសម្ភាសទាំងអស់ហ្នឹងគឺធ្វើឡើងនៅភូមិយ៉បាតអើសង្កាត់?

ខៈ ក្បាលកោះ។

កៈ ក្បាលកោះ ខ័ណ្ឌច្បារអំពៅ រាជធានីភ្នំពេញណេះយាយ?

ខៈ ចា៎!

កៈ បាទចឹងសំរាប់យាយឈ្មោះពេញរបស់យាយឈ្មោះអីគេយាយ?

ខៈ ខ្ញុំឈ្មោះរី។

កៈ បាទ?

ខៈ រី។

កៈ ឈ្មោះរី?

ខៈ ចា៎!

កៈ ឈ្មោះអីគេរីយាយ?

ខៈ ម៉ៅរីប្ដីគ្រូម៉ៅ។

កៈ អត់ទេឈ្មោះត្រកូលយាយហាសឪពុកយាយ?

ខៈ ឪពុកខ្ញុំឈ្មោះយ៉ង់។

កៈ យ៉ង់?

ខៈ ចាំ!

កៈ យ៉ង់រី?

ខៈ យ៉ង់រី។

កៈ អូ៎ចុះមានឈ្មោះហៅក្រៅអត់យាយ?

ខៈ អត់មានទេគេហៅតែរីចឹងម៉ង។

កៈ អូ៎ចុះកាលពីក្មេងធ្លាប់មាននរណាគេហៅឈ្មោះយាយអីផ្សេងពីហ្នឹងអត់?

ខៈ អត់មានទេយាយគេធ្លាប់តែហៅចឹងបណ្ដោយ។

កៈ អូ៎!

ខៈ អត់មានគេហៅពីនេះពីនោះអីអត់ទេ។

កៈ បាទយាយ!

ខៈ ចាំ!

កៈ សព្វថ្ងៃយាយអាយុប៉ុន្មានយាយ?

ខៈ ខ្ញុំមានខ្ញុំហាហុកសិបប្រាំបី។

កៈ ហុកសិបប្រាំបីហោសយាយ?

ខៈ ចាំ!

កៈ ចុះយាយកើតនៅថ្ងៃខែឆ្នាំណាយាយចាំទេ?

ខៈ ហ៎ស្រេចហើយដល់សួរថ្ងៃសួរខែឆ្នាំតែណុងពេលណុងរួចមកហើយ!

កៈ យាយកើតនៅឆ្នាំមួយពាន់ប្រាំបួនរយហាមួយចុះយាយអើឆ្នាំច័ន្ទគតិជូត ឆ្លូវ ខាល ថោះយាយឆ្នាំអីគេយាយ?

ខៈ ខ្ញុំឆ្នាំថោះ។

កៈ យាយឆ្នាំថោះណេះ?

ខៈ ចាំ!

កៈ យាយអ្នកកើតស្រុកកំណើតយាយយាយកើតនៅណាយាយ?

ខៈ ខ្ញុំកើតនៅក្បាលកោះនេះ។

កៈ នៅភូមិយ៉បាត ឃុំក្បាលកោះណេះយាយ?

ខៈ ចាំដូចក្មួយឯងនិយាយមិញដែរកន្លែងកើតចឹង។

កៈ បាទយាយបាទយាយមានបងប្អូនបង្កើតចំនួនប៉ុន្មាននាក់ទៅយាយ?

ខៈ ខ្ញុំបងប្អូនខ្ញុំប្រាំនាក់។

កៈ អូ៎យាយកូនទីប៉ុន្មានទៅ?

ខៈ ហ៎ក្នុងទីបីបីហើយ!

កៈ យាយកូណទីបីហេស?

ខៈ ចាំ!

កៈ អូ៎ចុះមានស្រីប៉ុន្មានប្រុសប៉ុន្មានយាយ?

ខៈ ប្រុសបីស្រីបី។

កៈ ប្រុសបីស្រីបី?

ខៈ ចាំ!

កៈ ប្រាំមួយនាក់ទាំងអស់ចឹងហោសយាយ?

ខៈ ចាំ!

កៈ
ចុះយាយគិតថាយាយអាចប្រាប់ឈ្មោះបងប្អូនយាយបានទេថាពួកគាត់មានឈ្មោះអីខ្លះយាយ
?

ខៈ អូ៎ឈ្មោះរាប់ពីបងពៅជ្រមកឈ្មោះយ៉ាតមួយ ឈ្មោះយ៉ំមួយ បឹងមួយ ខ្ញុំខ្ញុំសារី។

កៈ បាទ!

ខៈ ហើយបានស្រីនីនអស់ហើយ!

កៈ អូ៎ចុះមានន័យថាយាយពៅគេ?

ខៈ ចាំ!

កៈ អូ៎ចុះយាយគិតថាយាយធ្លាប់មានអនុស្សាវរីយ៍អីជាមួយបងប្អូនយាយអត់?

ខៈ ទេខ្ញុំអត់ដែរមានដើរទាស់ដើរជេអីអត់។

កៈ អូ៎!

ខៈ អត់មានទេបងប្អូនចិញ្ចឹមទៅវ៉ៃទៅកាប់គ្នាអត់។

កៈ អូ៎យាយធ្លាប់មានអនុស្សាវរីយ៍ជាមួយយាយអត់?

ខៈ ចាំ!

កៈ កាលនៅក្មេងហាសធ្លាប់ធ្វើអីគេខ្លះជាមួយគាត់អត់?

ខៈ
ខ្ញុំគេមានប្តីទៅមានអីខ្ញុំទៅធ្វើបន្លែខ្ញុំអត់មានដឹងទេប៉ុន្តែដឹងប្រវត្តិគាត់ផ្សេងដោតបន្លែខ្ទឹមដូចជាអីចឹងហាស!

កៈ កាលនៅក្មេងហោសយាយកាលនៅក្មេងជាមួយគាត់?

ខៈ ចាំគាត់មានប្តីហើយ!
កៈ អូ៎!

ខៈ ប្តីមករកខ្មៅរកលាសរកត្រីជាមួយឪពុកអីចឹង។

កៈ អូ៎បាទយាយ!

ខៈ
កំសត់ណាស់ប្រវត្តិយាយប្រាប់ចៅឯងយកខ្មៅរកលាសជួលដីគេមែនដីឯងទេដីគេជួលដាំបន្លែក្អួយអើយ!

កៈ
បាទយាយចុះយាយគិតថាយាយចូលចិត្តធ្វើអីគេជាមួយបងប្អូនយាយកាលនៅក្មេងយាយ?

ខៈ ធ្វើជម្មតាចេះតែរកបន្ទាស់រកអីចឹងដាំបន្លែកំប៉េកកំប៉ុក។

កៈ អូ៎បាទយាយ!

ខៈ បង្កុំគ្នាចឹងទៅ។

កៈ បាទយាយ!

ខៈ ចាំ!

កៈ ចុះយាយគិតថាបងយាយប្អូនយាយឥឡូវនៅណាយាយ?

ខៈ បងប្អូននៅហ្នឹងទាំងអស់។

កៈ បងប្អូនយាយ..?

ខៈ នេះនៅហ្នឹងនោះនៅហ្នឹងដែរធ្វើផ្ទះនៅហ្នឹង!

កៈ អូ៎ចឹងបងប្អូនយាយនៅហ្នឹងទាំងអស់គ្នា?

ខៈ ចាំ!

កៈ អូ៎ពួកគាត់ធ្វើអីគេយាយ?

ខៈ ចាំ!

កៈ បងយាយហើយហ្នឹងប្អូនយាយធ្វើអីគេទៅឥឡូវ?

ខៈ ខ្ញុំប្រាប់ឈ្មោះអស់មិញហើយ!

កៈ ប៉ុន្តែពួកគាត់ធ្វើអីគេរកស៊ីធ្វើអីគេ?

ខៈ អូ៎ពួកគាត់ចាស់ៗហើយអូ៎រកស៊ីស្អីក៏ធ្វើដែរអូន។

កៈ ស្អីក៏ធ្វើដែរយាយ?

ខៈ ហ្នឹងហើយៗរកស៊ីឈ្នួលគេក៏រកជម្មតារកត្រីក៏រកគេជួលចេះតែទៅទៅ។

កៈ អូ៎!

ខៈ សម័យណុងអីហ្នឹងហាសទៅរកអោយតែបានចេះតែរកផ្សំៗទៅ។

កៈ
អូ៎បាទចុះយាយគិតថាអើចឹងយាយមានកូនមានចៅច្រើនណេះយាយណេះបងប្អូនយាយមានកូនមានចៅអស់ហើយណេះយាយ?

ខៈ មានទាំងអស់អើចិញ្ចឹមកូនចៅផ្សេងខ្ញុំអត់សូវស្គាល់គេទេ។

កៈ អូ៎ចឹង..?

ខៈ ប្រវត្តិគេខ្ញុំមិនដឹងខ្ញុំដឹងតែប្រវត្តិខ្ញុំដឹងកូនចៅខ្ញុំអត់ដឹងទេ។

កៈ បាទចុះចឹងយាយគិតថាឪពុករបស់យាយឈ្មោះអីគេយាយ?

ខៈ ឈ្មោះយ៉ង់។

កៈ ឈ្មោះយ៉ត?

ខៈ យ៉ង់។

កៈ យ៉ង់?

ខៈ ចាំ!

កៈ ចុះឪពុកយាយឥឡូវ..?

ខៈ យ៉ង់ រីខ្ញុំឈ្មោះរី។

កៈ បាទ!

ខៈ គាត់ឈ្មោះយ៉ង់។

កៈ បាទចុះអើស្រុកកំណើតគាត់អ្នកនៅណាយាយ?

ខៈ ស្រុកកំណើត..។

កៈ អូ៎!

ខៈ នៅហ្នឹង!

កៈ បាទ!

ខៈ ចាំ!

កៈ ចុះម្ដាយយាយឈ្មោះអីគេ?

ខៈ ឈ្មោះនឿ។

កៈ នឿន?

ខៈ នឿ។

កៈ នឿចុះគាត់អ្នកនៅភូមិក្បាលកោះហ្នឹងដែរ?

ខៈ នៅហ្នឹង!

កៈ អូ៎!

ខៈ ដណ្ដឹងជាជិត។

កៈ អូ៎បាទយាយចុះឪពុករបស់យាយកាលពីមុនគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតហ្នឹងចិញ្ចឹមកូនចៅហាសយាយ?

ខៈ ជីវិតដាំបន្លែបោះកណ្ដាននិយាយឪពុក។

កៈ ឪពុកយាយ?

ខៈ អើឪពុកហ្អឹងបង់អើប្រាប់បង់ត្រីហ្អឹងគាត់រកតែត្រីចិញ្ចឹមទាចិញ្ចឹមអីទេ។

កៈ អូ៎!

ខៈ ចិញ្ចឹមជ្រូកចិញ្ចឹមទា។

កៈ ចុះម្ដាយយាយវិញគាត់ធ្វើអីគេយាយកាលពីមុនហាស?

ខៈ ចាំ!

កៈ ម្ដាយយាយគាត់ធ្វើអីគេកាលពីមុន?

ខៈ ខ្ញុំអត់ដឹងទេ។

កៈ ចុះយាយអាចប្រាប់តិចបានទេយាយ?

ខៈ
ខ្ញុំមិនដឹងពីប្រវត្តិគាត់ប្រវត្តិមានដីមានផ្លីចឹងទៅគាត់ដាំពោតដាំស្លឹកគ្រៃអើដាំសណ្ដែកអីចឹងទៅ។

កៈ អូ៎យាយអាចជួយប្រាប់គាត់ក៏បានដែរយាយអ្វីដែរគាត់អត់គាត់ភ្លេចចឹងហាសយាយ អូ៎ចុះយាយគិតថាឪពុកម្ដាយយាយស្លូតរឺមួយក៏កាច?

ខៈ ម៉ែខ្ញុំស្លូតអត់កាចទេម៉ែខ្ញុំស្លូតណាស់។

កៈ ឪពុកយាយស្លូតដែរ?

ខៈ អត់និយាយទេឪពុកស្លូតណាស់។

កៈ អូ៎!

ខៈ ម៉ែពុកខ្ញុំអត់ដែរវ៉ៃតបអ្នកណាអីអត់ទេអត់ទាំងអស់។

កៈ
បាទចុះយាយគិតថាយាយធ្លាប់មានអនុស្សាវរីយ៍ជាមួយឪពុកម្ដាយកាលយាយនៅក្មេងជាមួយគាត់អត់យាយ?

ខៈ អត់ទេខ្ញុំអត់មានទេ។

កៈ
លក្ខណៈថាអនុស្សាវរីយ៍យាយចងចាំដូចធ្លាប់ទៅបង់ត្រីជាមួយពួកគាត់ទៅស្រែទៅធ្វើចំការអីជាមួយពួកគាត់មានទេ?

ខៈ ទៅទៅបង់ត្រីបង់អីចឹងទៅបង់ត្រីបង់អីចឹង។

កៈ អូ៎ហ្អឹងមានណេះយាយណេះ?

ខៈ ចាំ!

កៈ អូ៎ចុះអើឪពុលរបស់យាយធ្លាប់ប្រាប់ពីប្រវត្តិកាលគាត់នៅក្មេងទៅយាយទេ?

ខៈ មិនសូវចាំទេអូនអើយអត់ចាំ។

កៈ ភ្លេចហើយណេះយាយ?

ខៈ ភ្លេចភ្លាំងអស់ហើយ!

កៈ ចុះម្តាយវិញធ្លាប់ប្រាប់ទេ?

ខៈ ម្តាយក៏អត់សូវដែរម្តាយហ្នឹងឪពុកខ្ញុំមិនសូវដឹងទេ។

កៈ អូ៎បាទយាយ!

ខៈ ព្រោះនៅតូចៗអត់សូវដឹងទេអត់ដឹងប្រវត្តិម៉េចអត់ដឹង។

កៈ អូ៎ចុះអើយាយតាខាងឪពុកយាយស្គាល់ឈ្មោះគាត់ទេ?

ខៈ ទេអត់មានទេខាងហ្នឹងភ្លេចឈឹងសូន្យ។

កៈ អូ៎!

ខៈ មិនដឹងគាត់អត់ដឹងឈ្មោះអីព្រោះគាត់ស្លាប់ខ្ញុំនៅតូច។

កៈ បាទយាយចុះយាយតាខាងម្តាយវិញយាយស្គាល់ឈ្មោះគាត់ទេ?

ខៈ យាយម៉ៅគាត់ឈ្មោះម៉ៅ។

កៈ ចុះតា?

ខៈ តាឈ្មោះកំប្រុក។

កៈ តាប្រុក?

ខៈ ចាំតាប្រុកយាយម៉ៅ។

កៈ អូ៎ចុះយាយមករស់នៅហ្នឹងយូនៅយាយ?

ខៈ គាត់នៅពីដើមគាត់នៅអ៊ុំស្តៅហោសគាត់សួររឹងងហ្នឹងហាសខ្ញុំហេស?

កៈ យាយនៅហ្នឹងយូរនៅ?

ខៈ អូ៎ខ្ញុំនៅមួយអាយូសហើយហ្នឹង!

កៈ អូ៎!

ខៈ តាំងពីតូចដល់ឥឡូវទៅ។

កៈ អូ៎!

ខៈ អត់មានទៅណាមកណាទេ។

កៈ ចុះអើយាយមានបងប្អូនកូនចៅដែរទៅរស់នៅក្រៅប្រទេសអត់យាយ?

ខៈ អត់មាន។

កៈ កូនចៅខាងប្តីខាងអីអត់មានដែរ?

ខៈ ខាងប្តីក៏អត់ខាងឪពុកក៏អត់ខាងញាតិក៏អត់ដែរ។

កៈ ចុះទៅរស់នៅខេត្តផ្សេងមានអត់យាយ?

ខៈ អត់។

កៈ ប៉ុន្តែបើទៅរស់នៅភ្នំពេញមាន?

ខៈ ភ្នំពេញមានកូនស្រីពីរ។

កៈ អូ៎បាទយាយចុះប្តីរបស់យាយឈ្មោះអីគេយាយ?

ខៈ ប្តីខ្ញុំឈ្មោះម៉ៅ។

កៈ ចុះឥឡូវគាត់ម៉ៅ?

ខៈ ស្លាប់យូរហើយ!

កៈ អូ៎!

ខៈ គាត់ស្លាប់ម្ភៃឆ្នាំហើយ!

កៈ អូ៎ស្លាប់យូរហើយណោះយាយ?

ខៈ ចា៎!

កៈ
ចុះអើពីមុនដែរគាត់ស្លាប់ពីមុនដែរគាត់បានយាយគាត់ធ្វើអីគេទៅសំរាប់ចិញ្ចឹមយាយចិញ្ចឹមកូនចៅ?

ខៈ គាត់ចិញ្ចឹមធ្វើស្រែគាត់ដាំបន្លែដាំបន្លុកគាត់មានដីពីដើម។

កៈ អូ៎ចឹងគាត់ធ្វើតែចំការទេណេះយាយ?

ខៈ គាត់អ្នកចំការ។

កៈ បាទយាយ!

ខៈ ខ្ញុំឪពុកខ្ញុំរកត្រីបង់សំណាញ់។

កៈ បាទយាយ!

ខៈ ដល់តែឃើញគេឃើញគេដណ្តឹងទៅ។

កៈ អូ៎!

ខៈ និយាយអោយអស់ចេះទៅ។

កៈ បាទយាយចុះយាយគិតថាយាយការការនៅឆ្នាំណាយាយ?

ខៈ ហ៎ការរួចហើយ!

កៈ យាយមានកូនប៉ុន្មាននាក់?

ខៈ ខ្ញុំប្រាំមួយនាក់។

កៈ ប្រាំមួយ?

ខៈ ប្រាំមិញហ្នឹង!

កៈ យាយកូនបងរបស់យាយអាយុប៉ុន្មាន?

ខៈ ហ៎!

កៈ យាយចាំអត់យាយ?

ខៈ មិនសូវចាំទេកូនគាត់ដឹងឆ្នាំអីៗទេភ្លេចភ្លាំងអស់ហើយ!

កៈ ប៉ុន្តែគ្រាន់ថាអើកូនយាយគាត់នៅណាខ្លះយាយ?

ខៈ កូនគាត់នៅភ្នំពេញពីរនាក់នៅគៀនស្វាយហ្នឹងពីរនាក់បីនាក់កូនគាត់ហោស!

កៈ អូ៎ចឹងគាត់មានចៅច្រើនហាសណេះយាយ?

ខៈ ចៅតិចដែរកូនគាត់។

កៈ អូ៎ចឹងមានន័យថាកូនគាត់អត់ទាន់មានកូនច្រើនទេណេះ?

ខៈ អត់មានច្រើនទេ។

កៈ អូ៎!

ខៈ មួយនោះគេឆ្ងូតតែបីនេះហើយ!

កៈ បាទចុះយាយគិតថាចឹងយាយពីក្មេងយាយធ្លាប់បានរៀនទេយាយ?

ខៈ ខ្ញុំ?

កៈ បាទ!

ខៈ អត់ឪពុកអោយទៅចារទូកខ្ញុំមិនបានទៅរៀនទៅសូត្រហ្នឹងគេទេ ឪពុកម្តាយក្រអត់បានចេះបន្តិចទេ។

កៈ បាទយាយចុះចឹងយាយគិតថាយាយកាលពីក្មេងយាយធ្លាប់មានមិត្តភក្តិទេយាយមិត្តភក្តិដែរស្និទ្ធិស្នាលហាស?

ខៈ អត់។

កៈ យាយធ្លាប់មានមិត្តភក្តិពីមុនទេ?

ខៈ អត់ទេខ្ញុំមេម៉ាយខ្ញុំចេញហ្នឹង!

កៈ អូ៎អត់ដែរមានមិត្តភក្តិទេណេះយាយណេះ?

ខៈ ហ្នឹងហើយ!

កៈ អូ៎!

ខៈ ខ្ញុំពិបាកម៉េចពេលមានប្តីទេការហើយរត់ចោលគេពីរបីសារខ្លាចគេ។

កៈ យាយធ្លាប់រត់ចោលប្តីដែរហោស?

ខៈ ខ្លាចគាត់ខ្លាចការហើយ!

កៈ អូ៎ខ្លាចប្តីហោស?

ខៈ ខ្លាចប្តីអត់ដឹងមិត្តភក្តិម៉េចផង។

កៈ អូ៎ចុះយាយគិតថានៅពេលដែរយាយការហើយយាយរត់ចោលប្តីហើយប្តីទៅយកយាយវិញរឺមួយក៏ម៉េច?

ខៈ អត់ទេគ្រាន់ថាយាយទៅយប់មកវិញមក។

កៈ អូ៎យាយរត់ទៅនៅណាយាយ?

ខៈ នៅស្រុកខាងប្តី។

កៈ អូ៎ដល់ពេលដែរយាយរត់ចោលគាត់ទៅយាយមកផ្ទះឪពុកម្តាយយាយ?

ខ៖ ចាំ!

ក៖ ដល់ពេលហើយប្ដីគាត់មកយកវិញ?

ខ៖ មកយកញាតិមិត្តភក្ដិអត់ដឹងមិត្តភក្ដិទេយ៉ាងអត់ដែរស្គាល់។

ក៖ អូ៎!

ខ៖ ម៉េចពួកម៉ាកម៉េច។

ក៖ មិត្តភក្ដិពួកម៉ាក?

ខ៖ ពួកម៉ាកមិត្តភក្ដិ។

ក៖ អូ៎ចុះយាយកើតអីបានយាយរត់ចោលប្ដីយាយ?

ខ៖
ខ្លាចគេណុងគេចំឡែកមកផ្ទះឯងអាអូនឯងចឹងហាសដណ្ដឹងគាត់ចឹងខ្លាចអាអូនឯងហ្នឹងចំឡែកចឹងមកនៅជាមួយ។

ក៖ អូ៎ប៉ុន្តែគាត់រត់បីដងចឹងមានន័យថាគាត់ការហើយបានគាត់រត់រឺមួយក៏មុនការ?

ខ៖
គាត់ការហើយការហើយចឹងអាអូនឯងចឹងដេកនៅជាមួយគ្នាចឹងលុកលាន់ប្ដីប្រពន្ធចឹងហាសណាស់។

ក៖ បាទ!

ខ៖ រួចក៏ខ្លាចខ្លាចក៏រត់មកផ្ទះមក។

ក៖ រួដល់ពេលហើយប្ដីមកយកទៅវិញទៀត?

ខ៖
ប្ដីយកទៅវិញទៀតទៅវិញទៀតដល់ចឹងយើងដេកម្ដងទៀតវាអត់លុកលាន់ទេបានពីរយប់បីយប់ចឹងអើមនុស្សដឹងស្រាប់ហើយលុកលាន់អង្អែលអីចឹងទៅក៏រត់មកទៀតមក។

ក៖ ដល់ពេលលើកក្រោយ..?

ខ៖ យាយហ្នឹងឆោតចង់ងាប់ហ្នឹងជំនាន់ហ្នឹង!

ក៖ រួចដល់ពេលលើកក្រោលើកទីបីបានរត់មក?

ខ៖ ឪពុកវ៉ៃ។

ក៖ ឪពុកវ៉ៃហោស?

ខ៖
ឪពុកវ៉ៃគេថាចឹងអញ៉ាមែនបានហែងគ្មានទេព្រោះប្រុសរស់បានតែប៉ុណ្ណឹងកូនហើយម្ដាយអីនិយាយណែនាំចាស់ៗគេណែនាំទៅចេះប្រឹងនៅផ្ទះទៅនៅផ្ទះមើលធម្មតាចឹងទៅ។

ក៖ អូ៎ចឹងបានបាននៅជាមួយគ្នាបានកូនចៅទៅ?

ខ៖ ចាំនៅជាមួយទៅ។

ក៖ ដល់ពេលហ្នឹងឈប់រត់ហើយណោះយាយណោះ?

ខ៖ ដល់ហើយឈប់រត់អត់ទៅខ្លាចឪពុកវ៉ៃឪពុកវ៉ៃដែរគាត់ស្លូតមែនតែគាត់..។

ក៖ គាត់វ៉ៃ?

ខ៖ ហ្នឹងគាត់រើសងបណ្ណាការគេដូចថាដឹងហើយដឹងហើយលែងរឹតហាស!

ក៖ បាទយាយចុះអើយាយគិតថាយាយធ្លាប់ធ្វើស្រែចំការណេះយាយណេះ?

ខ៖ ចាំ!

ក៖ ចុះនៅចំការយាយធ្វើអីគេដាំអីគេខ្លះទៅយាយ?

ខ៖ ចេះតែដាំគ្រប់សព្វដាំពោត សណ្តែកល្ហុងអីចេះតែដាំពេញហ្នឹង!

ក៖ បាទយាយយើងចេះតែដាំនេះដាំនោះហាសណេះយាយ?
ខ៖ ចេះតែដាំហើយអត់សល់អីទេកំប៉េកកំប៉ុកចេះតែដាំទៅអាណាផ្លែមុនបេះទៅ។

ក៖
បាទយាយត្រូវចុះយាយគិតថាអើតាំងពីក្មេងរហូតមកដល់ឥឡូវយាយធ្លាប់ធ្វើការងារអីគេខ្លះយាយ?

ខ៖ អត់ធ្វើអីកើតទេរកខ្មៅដល់ទៅរករកទៅយូរៗទៅឈឺៗអស់លុយក៏រត់មកនៅជាមួយកូនអត់មានលុយមើលខ្លួនទេ។

ក៖ អូ៎បាទយាយ!

ខ៖ រត់មកនៅជាមួយកូនគេចិញ្ចឹមរាល់ថ្ងៃ។

ក៖ បាទយាយ!

ខ៖ ស្មានតែមិនរស់ផងអើយកំសត់ណាស់។

ក៖ ចឹងហោសយាយ!

ខ៖ ហ្នឹងហើយស្មានតែរស់ហ្នឹង!

ក៖ កើតអីយាយ?

ខ៖ សូត្រមន្តសូត្រអីគេពិនិត្យទៅគេថារលាកទងសួត
ហើយគេថាខ្សោយបេះដូងហើយក៏លើសឈាមដល់ហើយប្រកាចប្រឈរភ្នែកើងលើចឹងទៅសូត្រមន្តសូត្រអីចឹងទៅអោយគាត់ទៅបានគាត់មានជីវិតជីវាំងដល់ឥឡូវវិញទៅ។

ក៖ អូ៎ចឹងមានន័យថា..?

ខ៖ វានៅជាប់ថ្នាំ។

ក៖ គាត់ឈឺច្រើនហោសយាយ?

ខ៖
ហ្នឹងហើយឈឺគ្រប់មុខចឹងហើយដល់ឥឡូវហ្នឹងទិញថ្នាំអោយលេបទៅជាប់ការរហូតថ្នាំអត់ដាច់ទេត្រូវតែបើថាត្រូវតែហត់លេបថ្នាំហត់ពេទ្យហាសមើលខ្ញុំហាស!

ក៖ អូ៎ចឹងមានន័យថាឥឡូវយាយនៅតែទៅពេទ្យចឹង?

ខ៖
អត់ទៅទេលែងទៅហើយគេអោយថ្នាំមកលេបនៅផ្ទះគាត់ចុកដៃចុកជើងចឹងឈឺក្នុងខ្លួនក្នុងប្រាណអស់ទិញថ្នាំហ្នឹងមកអោយគាត់លេបបាត់ហើយ!

ក៖ អូ៎!

ខ៖
ដល់មិនចឹងទេឥឡូវនេះនៅតែចុកត្រូវបាត់បាត់ត្រូវឈឺឈឺចឹងថ្ងៃហ្នឹងឈឺទៀតហើយចឹងទាល់ល្ងាចចឹងទៅលេបថ្នាំទៀតទៅ។

ក៖ បាទយាយប៉ុន្តែយាយឥឡូវនៅតែឈឺអាជំងឺបេះដូងអាជំងឺសួតជំងឺនៅតែឈឺដដែល?

ខ៖ នៅតែឈឺ។

ក៖ ចង់និយាយថាយាយត្រូវការថ្នាំជាប្រចាំរាល់ថ្ងៃអើរាល់ថ្ងៃមែនទេយាយ?

ខ៖ រាល់ថ្ងៃ។

ក៖ អូ៎!

ខ៖ អត់ដែរខានទេ។

ក៖ បាទយាយ!

ខ៖
ថ្នាំនៅទាំងកំប៉ុងៗតែខ្ញុំហ្នឹងក៏ថ្នាំរាល់ថ្ងៃអាក្បាលជង្គង់ហ្នឹងអាចង្កេះហ្នឹងវាធ្វើទុកតែចង្កេះក្បាលជង្គង់អាទ្រូងអីចឹងត្រូវចុកចុក។

ក៖ បាទយាយបាទ!

ខ៖ ត្រូវបាត់បាត់ទៅចុកចុក។

ក៖ អូ៎ចុះយាយគិតថាយាយកាលពីក្មេងយាយធ្លាប់លក់ដូរអត់យាយ?

ខ៖ ទើបលក់ដូរ។

ក៖ អូ៎!

ខ៖ លក់ខ្នៅលក់បង្គាអត់មានមុខរបរអីទេ។

ក៖ បាទយាយ!

ខ៖ ព្រោះអត់លុយរកដូចវាមិនមាន។

ក៖
បាទយាយចុះយាយគិតថាអើយាយកាលពីក្មេងយាយធ្លាប់ចិញ្ចឹមសត្វពីមុនអត់ចិញ្ចឹមមាន់?

ខ៖ គាត់ចិញ្ចឹមមាន់ ខ្ញុំចិញ្ចឹមជ្រូកចិញ្ចឹមមាន់ចិញ្ចឹម។

ក៖ គោក្របីទាអីយាយចិញ្ចឹមទេ?

ខ៖ អត់ទេក្របីហ៎ទាមាន់ចិញ្ចឹមក្របីអត់ទេ។

ក៖
បាទយាយបាទចុះយាយគិតថាអើជីវិតរបស់យាយកាលពីក្មេងម៉េចដល់ពេលឥឡូវមកផ្លាស់ប្តូរម៉េចដែរយាយ?

ខ៖ ឥឡូវសង្ឃឹមតែកូនមានលក់ដូរអីមានលក់ដូរអីកើតដើរអត់ទាំងរួចបាយអត់បាន។

ក៖ អូ៎!

ខ៖ បាយមិនបានប៉ុណ្ណេះរួចត្រីហ្នឹងឆ្ងាញ់ហាសបាយបានប៉ុណ្ណេះ។

ក៖ អូ៎!

ខ៖ ជួនណាអត់បានអីទាល់តែព្រឹកទៅទិញបបរអត់ទៀងហើយអត់ម៉ង។

ក៖ ប៉ុន្តែអត់ឃ្លានម៉ងហោស?

ខ៖ ដូចអត់ឃ្លាន។

ក៖ អូ៎!

ខ៖ ដូចថារបស់យើងអីឆ្ងាញ់ហ្នឹងមិនបានច្រើន។

ក៖ អូ៎បាទយាយ!

ខ៖ ហើយបានអីឆ្ងាញ់អូនអើយស៊ីបាយរាល់ថ្ងៃរកតែលុយទិញមិនបានផង។

ក៖ អូ៎!

ខ៖ ដឹងបានម្ហូបអីមានតែខ្ទៅលាសទេអោយតែបានស៊ីចូលតិចៗទៅចឹងបានថា។

ក៖ អូ៎!

ខ៖
ស៊ីជាមួយកូនជាមួយចៅតិចបានយើងរកអីមិនកើតតិចៗមានលុយក៏បានអោយឯងទៅចេះចឹងរកអីទៅលុកទៅដល់ពេលណាអាឃ្លានទៅទៅរកសុំលុយហែងទិញម្ហូបស៊ី។

ក៖ បាទយាយចុះយាយចូលចិត្តហូបម្ហូបអីគេយាយ?

ខ៖ ខ្ញុំ?

ក៖ បាទ!

ខ៖ ផ្ទុះធ្វើអី។

ក៖ ហូបណុងទៅ?

ខ៖ ហូបណុងដែរទៅ។

ក៖ អូ៎!

ខ៖ គេធ្វើគោកហូបគោកគេធ្វើទឹកហូបទឹកទៅគេត្រីត្រីហ្នឹងគេចឹង។

ក៖ បាទយាយ!

ខ៖ ធម្មតា។

ក៖ បាទយាយ!

ខ៖ យើងហូបកើតមិនកើតចេះតែហូប។

ក៖ បាទយាយត្រូវ?

ខ៖ គេអោយហើយហូបមិនកើតក៏មិនអី។

ក៖ បាទយាយយាយចេះច្រៀងអត់យាយ?

ខ៖ ចេះមិនដឹងច្រៀងម៉េចគាត់អត់ចេះច្រៀងទេ។

ក៖ យាយចេះរាំអត់យាយ?

ខ៖ ហ៉េរាំចេះបើថាច្រៀងវិញអត់ចេះទេ។

ក៖ យាយចូលចិត្តរាំហោស?

ខ៖ មានពិបាកអីចេះតែទៅតាមគេចេះតែទៅតាម។

ក៖ ចុះយាយគិតថាអើយាយចូលចិត្តមើលល្ខោនយីកេអាយ៉ៃអីទេយាយ?

ខ៖ ហ៎ល្ខោនយីកេអាយ៉ៃអីអោយតែលឺទៅ។

ក៖ មើលគាល់ចប់ហាសណេះយាយ?

ខ៖ ចប់ចប់ហើយរឿងល្ខោនអាយ៉ៃ។

ក៖ បាទ!

ខ៖ បើចំបីអីអត់ចូលចិត្តទេ។

ក៖
ចឹងហោសយាយយាយគិតថាមាននរណាគេមួយនៅក្នុងក្រុមគ្រួសារយាយចេះលេងឧបករណ៍ភ្លេងទេយាយ?

ខ៖ អត់ទេ។

ក៖ ភ្លេងខ្មែរភ្លេងសៀមអី?

ខ៖ អត់មានទេ។

ក៖ អូ៎ចឹងផ្ទះរបស់យាយមានលក្ខណៈបែបណាយាយតាំងពីក្មេងរហូតមកដល់ឥឡូវហាស
កាលពីក្មេងយាយនៅជាមួយឪពុកម្ដាយផ្ទះម៉េចដល់ពេលឥឡូវផ្ទះម៉េច?

ខ៖ ផ្ទះឬស្សីពីដើម។

ក៖ កាលពីក្មេងហ៎?

ខ៖ ប្រុងតែបង្កើតហើយណេះ។

ក៖ ចុះប្រកអីគេយាយ?

ខ៖ ស្បូវយើងជម្នគា។

ក៖ ប្រកស្លឹកយើងហោសអូ៎?

ខ៖ ហើយជញ្ជាំងឬស្សីយើងឬស្សីគេចាស់ៗគេច្រៀកហាសផ្ទាំងគេប៉ុនៗនេះ។

ក៖ កាលពីមុនយាយនៅណាយាយ?

ខ៖ នៅហ្នឹងប៉ុន្តែដីបាក់អស់ហើយ!

ក៖ អូ៎!

ខ៖ ដីបាក់ទៅទន្លេអស់ហើយដីថ្លីអី។

ក៖ រួចចុះយើងមកនៅហ្នឹងវិញ?

ខ៖ ដីគេហ្នឹង!

ក៖ អូ៎!

ខ៖ ជួលដីគេនៅហ្នឹងមួយខែដប់ម៉ឺន។

ក៖ អូ៎បាទយាយចុះយាយគិតថា..?

ខៈ អត់ដីនៅទេទៅសុំគេជួលគេទេ។

កៈ បាទយាយ!

ខៈ រកលុយទិញអត់បាន។

កៈ ចុះយាយគិតថាផ្ទះឥឡូវមានលក្ខណៈបែបណាយាយផ្ទះយាយឥឡូវនៅសព្វថ្ងៃហាស?

ខៈ នៅខ្ទមហាសនៅខ្ទមកូនហាស!

កៈ អូ៎យាយនៅក្នុងខ្ទមហេស?

ខៈ ចាំ!

កៈ យាយចែកគ្នានៅម្នាក់មួយខ្ទមហេស?

ខៈ ចាំខ្ញុំជួលនេះគាត់នៅលើដីខ្សាច់គេនេះ។

កៈ អូ៎!

ខៈ
ដីនេះដីរបស់គេផ្សេងទេដីហ្នឹងគេទិញអើរដ្ឋគេទិញអើប្រុងធ្វើអីទេដល់ពេលគេមិនទាន់ធ្វើចេះតែនៅសិនទៅខ្ញុំជួលដីគេទេ។

កៈ អូ៎ដល់ពេលដែរគេនៅអាហ្នឹងយើងចេញ?

ខៈ
ហ្នឹងហើយនេះគេដេញចេញកាលពីមុនធ្វើនៅហ្នឹងដែរតើគេនៅកន្លែងណាកន្លែងណឹស្រេចតែកូនចៅគេខ្ញុំចាស់ហើយខ្ញុំទៅណារួច។

កៈ បាទយាយចុះយាយគិតថាអើយាយមានបងប្អូនកូនចៅដែរចេះធ្វើផ្ទះអត់យាយ?

ខៈ អត់ទេបងប្អូនរឿងគេ។

កៈ អត់ចេះទេណេះយាយ?

ខៈ
និយាយរួមកូនក្មួយចេះធ្វើផ្ទះគេកូនក្មួយអីយើងធ្វើការធ្វើផ្ទះធ្វើអីទាល់តែទៅស្ដីគេទាល់មានលុយអោយគេបានបាន។

កៈ ចឹងហោសយាយ?

ខៈ វាអត់មកទេគេអត់ដែរ។

កៈ បាទយាយត្រូវចុះយាយគិតថាអើជំនាញអីដែរយាយចេះស្ទាត់ជំនាញយាយ?

ខៈ
អើស្ទាត់ជំនាញអីទេរាល់ថ្ងៃអូនអើយនៅតែផ្ទះចឹងមានស្ទាត់ជំនាញអីផងរាល់ថ្ងៃទៅណាអង្គុយបងប្អូនមើលមុខគ្នាពីរនាក់ម៉ង់ៗហ្នឹង!

កៈ ប៉ុន្តែកាលពីក្មេងហាសយាយ?

ខៈ
ពីក្មេងយើងជម្ពួតារកទៅត្រូវគេជួលទៅរកអីទិញអីធ្វើអីចេះតែទៅតាមគេទៅគេជួលយើងទៅធ្វើអីទៅទៅ។

កៈ បាទយាយ!

ខ៖ មួយថ្ងៃប្រាំពីរប្រាំបីពាន់មួយម៉ឺនអីចឹងទៅ។

ក៖ បាទយាយ!

ខ៖ គេជួលចេះតែទៅតាមគេទៅហ្នឹងមានតែប៉ុណ្ណឹង។

ក៖ បាទ!

ខ៖ មានស្អីទៀតទេ។

ក៖ ចុះ..?

ខ៖ ឥឡូវនេះអង្គុយមើលមុខគ្នា។

ក៖ ចុះយាយគិតថាឪពុកម្តាយយាយធ្លាប់បង្រៀនពីជំនាញអីទៅយាយអត់?

ខ៖ ជំនាញអីជំនាញតែបង់ត្រីហ្នឹងខ្ញុំដឹងក្តីមក។

ក៖ អូ៎!

ខ៖ គាត់បង់ទាល់តែគាត់ចាស់ខូច។

ក៖
បាទយាយយាយអាចប្រាប់ពីការលំបាកតាំងពីក្មេងបានទេយាយយាយមានការលំបាកអីតាំងពីក្មេងយាយ?

ខ៖ ទេកាលពីក្មេងវាលំបាករត់តាមម៉ែឪខែរដាធ្លាក់ខ្យល់។

ក៖ ចុះយាយ..?

ខ៖ វាអត់ពិបាករឿងអីទេអត់មាននរណាវៃនរណាដំអីវាអត់ទេ។

ក៖ ចុះកាលពីជំនាញលុនណុលប៉ុលពតយាយ?

ខ៖
អូ៎ជំនាញប៉ុលពតនេះអោយទៅធ្វើការមនុស្សយើងចឹងអោយធ្វើព្រៃពោតព្រៃអីសណ្តែកខ្ញុំអត់ទៅណាទេ។

ក៖ យាយគេជំលាសទៅណាយាយពេលហ្នឹង?

ខ៖ អត់ជំលាសស្អីទេខ្ញុំនៅហ្នឹងគាត់នៅហ្នឹងម៉ង។

ក៖ អូ៎!

ខ៖
ប៉ុនគេអោយដាំសណ្តែកហើយដាំល្ងយាយនេះធូនអានេះដាក់ខ្សែភ្លើងចូលនេះតិចតែក្មេងបៀមឆក់ងាប់អត់អីទេអាហ្នឹងអត់ទេ។

ក៖ អត់ឆក់ទេយាយ?

ខ៖ វាអត់ដាក់ដាក់អត់វាអត់ឆក់ទេ។

ក៖ អូ៎ចុះយាយគិតថាពេលប៉ុលពតគេអោយយើងធ្វើអីទៅយាយ?

ខ៖ វាអោយប្រើយើងទៅធ្វើសណ្តែកធ្វើល្ងដូចជាធ្វើតែយើងពីដើមចឹង។

ក៖ អូ៎!

ខៈ
អោយទៅដាំលូទៅដាំសណ្ដែកដាំស្រូវកាប់ចាំងមានស្រូវអីទៅច្រូតទៅវារែវវាអីសព្វបែបសព្វយ៉ាងចឹងដូចតែយើងធ្វើពីដើម។

កៈ អូ៎ចុះអើ..?

ខៈ វាអត់ធ្វើយើង។

កៈ របបអាហារម៉េចដែរយាយកាលជំនាន់ហ្នឹង?

ខៈ ហេ៎អាហារអីអត់ទេស្រាប់មិនបាច់ធ្វើ។

កៈ ចង់និយាយថា..?

ខៈ ម្ហូបអាហារ។

កៈ អើម្ហូបអាហារកាលជំនាន់ណុង?

ខៈ អូ៎ម្ហូបយើងវាធ្វើបបរបបរទៅវាធ្វើបាយបាយទៅ។

កៈ អូ៎ចឹង..?

ខៈ ស្រេចតែវាអោយស៊ីស្រេចតាមតែវាអយស៊ីទេអាសត្វហ្នឹងនោះ។

កៈ អូ៎បាទយាយបាទ!

ខៈ វាអោយឯងស៊ីបាយទន្ទន់ៗសណ្ដៗចឹងហាសចៅ។

កៈ ចុះឪពុកម្ដាយយាយពេលហ្នឹងនៅណាយាយ?

ខៈ ចាំ!

កៈ ឪពុកម្ដាយយាយនៅហ្នឹងដែរហោស?

ខៈ នៅហ្នឹង!

កៈ អូ៎!

ខៈ ជំលាសទៅអស់ប៉ុនចាស់អត់អីទេគេដឹករទេះទៅបានបាយមួយវែក។

កៈ បាទយាយ!

ខៈ សំលម្ជូរក៏ដោយប្រហុកក៏ដោយស្អីក៏ដោយវាអោយតាមតែចិត្តវាទៅណាស់។

កៈ
បាទយាយចុះយាយគិតថាអើចឹងសំរាប់ពេលដែរយាយនៅប៉ុលពតយាយអាយុប៉ុន្មានយាយពេលហ្នឹង?

ខៈ ខ្ញុំកាលនៅអាពតហេសហាជាងទេ។

កៈ អូ៎យាយអាយុហាជាងហើយហោស?

ខៈ ចាំ!

កៈ អូ៎រួចចុះយាយពេលហ្នឹងគេអោយយាយទៅមើលក្មេងៗមែន?

ខៈ អត់ទេខ្ញុំធ្វើចំការរហូតអត់មានរួមទៅណាអីទេ។

កៈ រួចចុះពេលណុងយាយមានកូនប៉ុន្មានពេលយាយប៉ុលពតហាស?

ខ៖ ខ្ញុំទើបបានពីរទេ។

ក៖ ពីរណេះយាយ?

ខ៖ ស្រីពីរ។

ក៖ អូ៎រួចចុះយាយគិតថាអើដល់ដាច់ប៉ុលពតហាសយាយមានការលំបាកអីទេយាយ?

ខ៖ ដាច់អាពតអត់អីទេចេះតែរកធម្មតាហ្នឹងចៅចេះតែរកទៅចៅអើយ។

ក៖ អូ៎!

ខ៖ លក់ខ្ទោលក់លាសលក់អីចឹងចិញ្ចឹមកូនរហូតសព្វថ្ងៃទាល់តែខ្លួនឈឺធ្វើអីលែងកើត។

ក៖ បាទយាយចុះយាយគិតថាសំរាប់ដូចជាពេលណាដែរយាយគិតថាយាយសប្បាយយាយ?

ខ៖
ពេលណាសប្បាយខ្ញុំអើយរកសប្បាយណាមិនឃើញវាចូលឆ្នាំចូលអីឆ្លៀតរាំវង់រាំអីហ្នឹងគេតិច។

ក៖ អូ៎អាហ្នឹងសប្បាយហាសណេះយាយណេះ?

ខ៖ ចាំអាហ្នឹងសប្បាយបានតែពីរបីថ្ងៃចឹងទៅ។

ក៖ បាទយាយ!

ខ៖ នេះបើនិយាយទៅចឹងហាស!

ក៖ បាទ!

ខ៖
កាលណុងវាត្រូវទៅការអានេះអានោះតិចសួរៗទៅវាចេះតែទៅលេងគេឯងទៅបានសប្បាយបីថ្ងៃចឹងទៅ។

ក៖ បាទយាយ!

ខ៖ រួចដល់ពេលទៅនោះរកស៊ីលក់ដូរទៀតទៅ។

ក៖ អូ៎ចុះរហូតមកដល់ជីវភាពសព្វថ្ងៃយាយម៉េចដែរយាយឥឡូវ?

ខ៖ ខ្ញុំសព្វថ្ងៃមានអីទេស៊ីតែកូនចៅគេចិញ្ចឹមនៅលរោង។

ក៖ អូ៎!

ខ៖ នៅជាមួយកូនមានលក់លាសលក់ខ្ទោចិញ្ចឹម។

ក៖ ចឹងហោសយាយ?

ខ៖ ចាំអត់មានអីទៀតទេមានតែប៉ុណ្ណឹង!

ក៖ អូ៎បាទចុះយាយគិតថាអើចឹងយាយអត់មានធ្វើអីទេ
ឥឡូវនៅតែអោយកូនចៅចិញ្ចឹមហាសណេះយាយ?

ខ៖
ចាំអត់ធ្វើអីកើតទេចេះតែញ័រដៃញ័រជើងចឹងដើរទគ្រេតទគ្រើកៗអត់ធ្វើអីកើតតែចានគេមិនអោយលៀងផងធ្វើអីមិនកើតទេត្រូវតែញ័រៗចឹងធ្វើអីមិនកើត។

ក៖ បាទយាយ!

ខ៖ បាត់ទៅៗចឹង។

កៈ អ៊ូចឹងយាយនៅមើលតែចៅៗទេណេះយាយណេះ?

ខៈ ចា៎!

កៈ
ចុះយាយគិតថាកាលពីក្មេងយាយធ្លាប់មានគោលបំណងថាធំឡើងយាយចង់ធ្វើអីមួយទេយាយ?

ខៈ ចង់ចង់ប៉ុនអត់មានការអីធ្វើទេមានការងារអីធ្វើ។

កៈ យាយអត់ចង់ធ្វើអីទេណេះ?

ខៈ ចា៎មានអីធ្វើអត់។

កៈ
ចុះយាយគិតថាបើសិនជាចង់អោយយាយផ្ដែផ្ដាំទៅកូនចៅក្មេងៗចៅៗចៅទួតអីយាយចង់ផ្ដែផ្ដាំអីទៅពួកគាត់ដែរយាយ
យាយចង់ផ្ដែផ្ដាំដើម្បីអោយពួកគាត់ខំប្រឹងធ្វើអំពើល្អអីចឹងហាស?

ខៈ
មានស្អីគ្រាន់តែចៅមកប្រដែលប្រដៅយើងចឹងទៅចៅខំរៀនខំធ្វើការអោយបានចេះធ្វើគ្រូបង្រៀនគ្រូអីគេចឹងទៅប្រដៅចៅអី។

កៈ
អ៊ូបាទយាយចុះបើសិនចង់អោយគាត់ជៀសវៀងវិញគិតថាចង់អោយពួកគាត់ជៀសវៀងពីអំពើអីដែរអត់ល្អហាសយាយ?

ខៈ ចា៎មានស្អីទៀតមានតែប្រដែលប្រដៅចៅអោយធ្វើអំពើល្អក្នុងសង្គមកុំធ្វើអំពើអាក្រក់។

កៈ បាទយាយមានអីផ្សេងដែរយាយចង់និយាយទៀតអត់យាយ?

ខៈ អត់ទេអត់មានអីទៀតទេអត់ទេ។

កៈ អស់ហើយណេះយាយ?

ខៈ ចា៎!

កៈ
ចឹងចុងក្រោយចៅអរគុណច្រើនយាយដែរបានអោយចៅពិភាក្សាជាមួយយាយទាក់ទងពីប្រវត្តិរបស់យាយចឹងហាសយាយ?

ខៈ ចា៎!

កៈ បាទអរគុណច្រើនយាយ។

ខៈ ចា៎សាធុប។